# លក្ខណៈទូទៅនៃកុលាលភាជន៍ខ្មែរសម័យអង្គរ (ភាគ២)

ក្នុងអត្ថបទមុន[១] ខ្ញុំបានបង្ហាញខ្លះហើយអំពីពាក្យកុលាលភាជន៍ ដែលមានន័យថា វត្ថុសម្រាប់ដាក់ ឬផ្ទុកធ្វើអំពីដីឥដ្ឋដុត។ ក្នុងអត្ថបទនេះខ្ញុំ និងលើកយកពីលក្ខណៈទូទៅ ដែលអ្នកសិក្សាអំពីកុលាលភាជន៍ បានកំណត់លើអត្តសញ្ញាណផលិតផលភាជន៍ដែលមានផលិតនៅក្នុងប្រទេសខ្មែរនាសម័យអង្គរ។

តើគេបែងចែកកុលាលភាជន៍ខ្មែរនាសម័យអង្គរយ៉ាងដូចម្តេច?

ដើម្បីឱ្យងាយស្រួលក្នុងការយល់ និងធ្វើចំណាត់ថ្នាក់លើកុលាលភាជន៍ដែលរកបានពីបណ្តាឡបុរាណ និងស្ថានីយប្រវត្តិសាស្ត្រនានា អ្នកសិក្សាអំពីកុលាលភាជន៍បានព្យាយាមបែងចែកភាជន៍ទាំងនោះតាមចំនុចសំខាន់ៗមួយចំនួន ដូចជាៈ

**១.គុណភាព**

គុណភាពគឺសំដៅទៅលើការដុតឬការផ្តល់កំដៅដល់ភាជន៍។ ជាធម្មតាកុលាលភាជន៍ខ្មែរក្នុងសម័យអង្គរត្រូវបានគេដុតនៅក្នុងឡបិទជិត ហើយសីតុណ្ហភាពគឺអាចមានចាប់ពី៩០០អង្សាសេរហូតដល់១១០០ឬ១២០០អង្សាសេ។ ប៉ុន្តែ យើងសង្កេតឃើញមានភាជន៍ជួនកាលក្បឿង មួយចំនួនអាចទទួលកំដៅក្នុងសីតុណ្ហភាពទាប គឺអាចត្រឹម៦០០ទៅ៧០០អង្សាសេ ដោយសារតែមានចំនុច២យ៉ាង គឺៈ (ក) អាចជាការដុតលើកទីមួយ មុននឹងយកមកលាបទឹករលោង (Glaze)។ (ខ) ដោយសារភាជន៍ ឬក្បឿងទាំងនោះនៅឆ្ងាយពីប្រភពកំដៅ (ភាជន៍ច្រើន យើងរកឃើញនៅផ្នែកខាងក្រោយ ក្បែរបំពង់ផ្សែង) ជាហេតុធ្វើឱ្យវាមិនអាចទទួលកំដៅខ្លាំងដូចភាជន៍ដែលគេរៀបចំនៅក្បែរភ្លើង។ ដោយសារតែការទទួលកំដៅមិនដូចគ្នានេះហើយទើបអ្នកសិក្សាអំពីភាជន៍របស់ខ្មែរ ព្យាយាមបែងចែកភាជន៍ទាំងនេះជា២គុណភាព គឺៈ (ក)ភាជន៍រឹង (Stoneware) និង(ខ) ភាជន៍ផុយ (Eartheware)។

**២.ការលាបស្រទាប់រលោង**

[១] សុខ កែវ សុវណ្ណារ៉ា (២០២១)

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា

ស្រទាប់រលោង (Glaze) គឺជាប្រភេទថ្នាំម្យ៉ាងដែលផ្សំឡើងពីទឹក ផេះ ខ្សាច់ ដែក ឬសារធាតុផ្សេងៗមួយចំនួនទៀតសម្រាប់ផលិតពណ៌ស្រទាប់រលោងនោះ។ តាមការរកឃើញកុលាលភាជន៍នៅតាមស្ថានីយកំណាយ ប្រាសាទបុរាណ ពិសេសនៅតាមឡបុរាណក្នុងតំបន់អង្គរ បង្ហាញថា ភាជន៍នៅសម័យនោះមានលាបស្រទាប់រលោងផ្សេងៗគ្នា ទៅតាមប្រភេទ និងទំហំភាជន៍។ ភាជន៍ខ្លះពុំមានលាបស្រទាប់រលោងទេ។ ដូចនេះគេបែងចែកជាដំបូងសម្រាប់ចំណាត់ថ្នាក់លក្ខណៈបែបហ្នឹង គឺភាជន៍ដែលមិនមានលាបទឹកស្រទាប់រលោង (Unglazed ware) និងភាជន៍ដែលមានលាបទឹកស្រទាប់រលោង (Glazed ware)។ ចំពោះភាជន៍ដែលមិនមានទឹកស្រទាប់រលោង គេមិនបែងចែកអ្វីផ្សេងទៀតទេ។ រីឯភាជន៍ដែលមានស្រទាប់រលោងគេ បែងចែកទៅតាមពណ៌របស់ស្រទាប់រលោងនោះមានដូចជាៈ ស្រទាប់រលោងពណ៌បៃតង (Green) បៃតងប្រផេះ (Greyish Green) ពណ៌លឿងខ្ចី (Pale Yellow) ពណ៌លឿងចំបើង (Yellow) និងពណ៌ត្នោត (Brown)។ ភាជន៍ខ្លះត្រូវបានគេលាបស្រទាប់រលោងចំនួន២ពណ៌ ឧទាហរណ៍ បំណែកភាជន៍រកឃើញនៅប្រាសាទតុបខាងលិច មានលាបពណ៌បៃតង និងពណ៌ត្នោត។[២] ភាជន៍នៅតាមបណ្តាឡមួយចំនួនពុំមានលាបទឹកស្រទាប់រលោងទេ តែមានលាបទឹកដីឥដ្ឋ (Clay Slip) ដែលមានជាតិដែកច្រើន ធ្វើភាជន៍មានសភាពរឹងខ្លាំង និងរលោងដូចលាបជ័រឈើ ឧទាហរណ៍ដូចជាភាជន៍នៅឡសរសើ[៣] និងឡបង្កោង[៤] ដែលភាជន៍មានពណ៌ប្រភេទនេះត្រូវបានលោក Groslierដាក់នាមឱ្យថា ***ភាជន៍មានពណ៌ស្រាក្រហមទំពាំងបាយជូ*** (Lie de Vin)។[៥] ដូចនេះយើងអាចកំណត់លើចំនុចនេះបានជាៈ (ក) ភាជន៍គ្មានស្រទាប់រលោង (Unglazed ware)។ (ខ)ភាជន៍មានស្រទាប់រលោង (Glazed Ware) ដែលអាចមានពណ៌បៃតង លឿង និងត្នោត។ (គ)ភាជន៍មានលាបទឹកដីឥដ្ឋ (Slipped ware) ជាទូទៅមានពណ៌ក្រហមចាស់ ឬក្រហមត្នោត។

---

[២] Sok Keo Sovannara, (2012:205)

[៣] សុខ កែវ សុវណ្ណារ៉ា (២០០៣)

[៤] ឆាយ រចនា និងទាំងអស់, (២០១០)

[៥] Bernard Phillipe, Groslier (1981)

### ៣.ប្រភេទ ឬរូបរាង

ជាធម្មតា អ្នកសិក្សាលើភាជន៍តែងធ្វើការបែងចែកភាជន៍ ឬបំណែកភាជន៍ដែលរកបាន ជាដំបូង គឺការចំណាត់ថ្នាក់លើរូបរាង ឬប្រភេទរបស់វាទាំងនោះ។ បន្ទាប់មកទើបគេបែងចែកទៅតាមគុណភាព និងស្រទាប់រលោង។ តាមការសិក្សាអំពីកុលាលភាជន៍ខ្មែរ ដោយជនជាតិបរទេស និងជនជាតិខ្មែរ គេបែងចែកភាជន៍ទាំងនោះទៅតាមឈ្មោះ ឬពាក្យខ្មែរដែលប្រើសព្វថ្ងៃ។ ការសិក្សាកុលាលភាជន៍នៅឡអន្លង់ធំជាលើកដំបូង លោក ឆាយ វិសុទ្ធ និងកញ្ញា ចាប សោភាព៉បានបែងចែកភាជន៍ខ្មែរចំនួន ១៤ប្រភេទ[៦] គឺ ជន្ទាប់ ខ្ចប កោដ្ឋ ពែង ចានក្រឡោម ក្រឡ កន្ទិន ក្អម ផើង ពាង ក្បឿងផ្ការ ក្បឿងផ្កាប់ ក្បឿងសន្ទឹករកា និងក្បឿងរងស្បូវ។ ការសិក្សាកុលាលភាជន៍នៅតាមបណ្តាឡផ្សេងៗទៀត ក៏រកឃើញមានភាជន៍ដែលមានរូបរាងដូចនៅឡអន្លង់ធំនេះដែរ ដូចជាឡខ្នារពោធិ[៧] និងឡតានី[៨]ជាដើម។ រូបរាងភាជន៍ទាំងនេះមានដូចជា៖

#### ក.ជន្ទាប់

ជន្ទាប់ដែលរកឃើញនៅតាមបណ្តាឡទាំងនោះ ភាគច្រើនជាភាជន៍តូច ដែលមានទំហំអង្កត់ផ្ចិតពី២.៥សង់ទីម៉ែត្រទៅ៦សង់ទីម៉ែត្រ និងកម្ពស់ប្រហែល៥សង់ទីម៉ែត្រ។ ជាទូទៅ យើងឃើញមានពីរបែប គឺជន្ទាប់មានបាតមូល (រូបលេខ១) និងជន្ទាប់មានជើងខ្ពីបន្តិច (រូបលេខ២)។ ជន្ទាប់ទាំងនេះភាគច្រើនជាភាជន៍រឹង មានស្រទាប់រលោងពណ៌បៃតង ឬពណ៌លឿង។

#### ខ.ខ្ចប

ខ្ចបជាភាជន៍តូច និងធំល្មម មានក្អេងធំ កតូច និងមាត់រីក ដូចផ្លែពួច។ ខ្ចបខ្លះធំអាចមានក្អេងទំហំប្រហែល១០ទៅ១៥សង់ទីម៉ែត្រ និងកម្ពស់១៥ទៅ២០សង់ទីម៉ែត្រ។ ភាជន៍ទាំងនេះភាគច្រើនរឹង និងមានស្រទាប់រលោងពណ៌បៃតង និងពណ៌ត្នោត (រូបលេខ៣)។

---

[៦] ឆាយ វិសុទ្ធ និងចាប សោភាព៉, (២០០២)

[៧] ឯម សុជាតា, (២០០៤)

[៨] The Agency for Culture Affaire (2000)

**គ.កោដ្ឋ**

ជាភាជន៍មានរាងស៊ីឡាំង បាតសំប៉ែត មានគម្របទាល ខ្ទះស្រួចជាថ្នាក់ឡើងលើ។ កោដ្ឋមានទំហំធំល្មម អង្កត់ផ្ចិតពី៦ទៅ១០សង់ទីម៉ែត្រ និងកំពស់ពី១០ទៅ១៥សង់ទីម៉ែត្រ។ កោដ្ឋជាភាជន៍រឹង និងមានស្រទាប់រលោងពណ៌បៃតង និងលឿង (រូបលេខ២)។

**ឃ.ពែង**

ពែងជាភាជន៍តូចៗល្មម ទំហំអង្កត់ផ្ចិតពី៥ទៅ៨សង់ទីម៉ែត្រ និងកំពស់ប្រហែល៧ **សង់ទីម៉ែត្រ។ ពែងមានក្អេងត្រង់ និងបាតរាបស្មើ ជាភាជន៍រឹង លាបទឹកដីឥដ្ឋ (រូបលេខ៥)។** ភាគច្រើនឃើញមានផលិតនៅឡសរសី និងបង្កោង។

**ង.ចានក្រឡោម**

ចានជាប្រភេទចានក្រឡោម មានបាតសំប៉ែត ក្អេងរាវ រីកចេញក្រៅ និងគែមមាត់ស្លួចធ្លាក់ចេញក្រៅ (រូបលេខ៦)។ វាមានទំហំពី១០ទៅ១៨សង់ទីម៉ែត្រ និងកម្ពស់ពី៨ទៅ ១០សង់ទីម៉ែត្រ។ ចានជាភាជន៍រឹង មានស្រទាប់រលោងពណ៌បៃតង និងពណ៌លឿង។

**ច.ក្រឡ**

ក្រឡជាភាជន៍មានបាតតូច ក្អេងធំ និងមាត់ទូលាយ។ វាមានទំហំក្អេងប្រហែលពី ១០ទៅ១៨សង់ទីម៉ែត្រ និងកម្ពស់ពី១៥ ទៅ២៥សង់ទីម៉ែត្រ។ ភាជន៍ទាំងនេះមានគុណភាពរឹង និងមានស្រទាប់រលោងពណ៌បៃតង (រូបលេខ៧)។

**ឆ.កន្ទិន**

កន្ទិនជាភាជន៍មានរាងដូចក្រឡ ប៉ុន្តែមាត់របស់កន្ទិនតូចជាង។ វាមានទំហំអង្កត់ផ្ចិតក្អេងពី១៥ទៅ២៥សង់ទីម៉ែត្រ និងកម្ពស់ពី២០ទៅ៣០សង់ទីម៉ែត្រ។ វាជាភាជន៍មានគុណភាពរឹង ខ្លះពុំមានស្រទាប់រលោង និងភាគច្រើនមានស្រទាប់រលោងពណ៌បៃតងប្រផេះ (រូបលេខ៨)។

**ជ.ក្អម**

ក្អមដែលរកបាននៅតាមបណ្តាឡក្នុងតំបន់អង្គរ មានរូបរាងខុសពីក្អមផលិតក្នុងពេលបច្ចុប្បន្ន។ ជាធម្មតា ក្អមទាំងនេះមានរាងដូចស្ករ ឬផ្លែពួច ពោលគឺមានបាតរាបស្មើ ក្អេងប៉ោង កស្លួច និងមាត់បើករីកចេញក្រៅ (រូបលេខ៩)។ វាមានទំហំធំល្មម អង្កត់ផ្ចិត

ក្អេងពី១៨ទៅ២៥សង់ទីម៉ែត្រ និងកម្ពស់ពី២៥ទៅ៣០សង់ទីម៉ែត្រ។ វាមានគុណភាពរឹង ខ្លះគ្មានស្រទាប់រលោង (តែមានលាបទឹកដីឥដ្ឋ ពិសេសនៅឡខ្នារពោធិ និងឡបង្កោង) ខ្លះមានស្រទាប់រលោងពណ៌បៃតង និងលឿងចំបើង។

**ញ.ផើង**

ជាភាជន៍មានបាតរាបស្មើ និងមានរន្ធមួយនៅចំកណ្តាល មានក្អេងធំ រីកចេញក្រៅ មាត់បើកចំហ (រូបលេខ១០)។ វាមានទំហំប្រហែល៣០ទៅ៣៥សង់ទីម៉ែត្រ និងកម្ពស់ប្រហែល៣០ទៅ៤៥សង់ទីម៉ែត្រ។ ផើងមានគុណភាពរឹង តែមិនមានលាបស្រទាប់រលោងទេ។

**ដ.ពាង**

ពាងជាភាជន៍មានរាងដូចផើង តែខុសត្រង់មិនមានរន្ធចំកណ្តាលនៅបាត (រូបលេខ១១)។ វាមានទំហំប្រហែល៣០ទៅ៤៥សង់ទីម៉ែត្រ និងកម្ពស់ប្រហែល៣០ទៅ៤០សង់ទីម៉ែត្រ។ ពាងមានគុណភាពរឹង តែពុំមានស្រទាប់រលោងទេ។

**ឋ.ក្បឿងផ្ទារ**

ក្បឿងផ្ទារ ឬញី ជាប្រភេទភាជន៍សម្រាប់សំណង់ស្ថាបត្យកម្មប្រាសាទ និងអគារផ្សេងៗ។ ក្បឿងប្រភេទនេះមានរាងតូចរាវនៅខាងចុង (ក្រោម) រីកនៅខាងលើ និងមានដោះមួយនៅផ្នែកខាងក្រោមសម្រាប់ទាក់និងដៃរណែងដំបូល (រូបលេខ១២)។ វាមានទំហំទទឹងប្រហែល១០ទៅ១៤សង់ទីម៉ែត្រ បណ្តោយពី២០ទៅ២៣សង់ទីម៉ែត្រ និងកម្ពស់៥ទៅ៧សង់ទីម៉ែត្រ។ វាមាន២គុណភាព គឺផុយ (មិនមានស្រទាប់រលោង) និងរឹង (គ្មានស្រទាប់រលោង និងមានស្រទាប់រលោងពណ៌បៃតង)។

**ឌ.ក្បឿងផ្កាប់**

វាមានរាងដូចក្បឿងផ្ទារ តែមានលក្ខណៈផ្ទុយគ្នា គឺមានរាងរីកធំនៅខាងក្រោម រួមតូចនៅខាងលើ និងមានដោះស្រួចវែងនៅខាងក្នុង សម្រាប់ទាក់និងក្បឿងផ្ទារ (រូបលេខ១៣)។ វាមានទំហំ និងគុណភាពដូចក្បឿងផ្ទារដែរ។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## ឈ.ក្បឿងវង់ស្បូវ

ជាក្បឿងនៅចុងបញ្ចប់ផ្នែកខាងក្រោមនៃដំបូល មានរាងជាត្របកឈូកបញ្ឈរ ឬជាក្បាលនាគជាដើម (រូបលេខ១៤)។ ជាធម្មតា ក្បឿងនេះផ្សំឡើងពីក្បឿងផ្កាប់នៅផ្នែកខាងក្រោយ និងក្បាច់ក្បាំងនៅផ្នែកខាងមុខ។ ក្បាច់ក្បាំងនេះមានក្បាច់លម្អផ្សេងៗ ដូចជាត្របកឈូក ក្បាលនាគ ឬគ្រុឌចាប់នាគជាដើម។ វាមានទំហំ និងគុណភាពដូចក្បឿងផ្កាប់ដែរ។

## ញ.ក្បឿងសន្ទឹករកា

ជាក្បឿងព្រំដំបូល មានរាងដូចត្រយ៉ូងចេកបញ្ឈរ។ វាផ្សំឡើងពីក្បឿងផ្កាប់ និងជន្ទួញដែលមានរាងថ្នាក់ៗ និងស្រួចនៅផ្នែកខាងលើ (រូបលេខ១៥)។ វាមានទំហំប៉ុនក្បឿងផ្កាប់ និងកម្ពស់ពី៣០ទៅ៤០សង់ទីម៉ែត្រ។ ក្បឿងទាំងនេះមានគុណភាពរឹង ខ្លះគ្មានស្រទាប់រលោង និងខ្លះទៀតមានស្រទាប់រលោងពណ៌បៃតង។

ជាសង្ខេប នេះជាចំនុចចាប់ផ្តើម និងជាលក្ខណៈទូទៅក្នុងការយល់អំពីការសិក្សាកុលាលភាជន៍ខ្មែរនាសម័យអង្គរ។ ការសិក្សាលម្អិតលើសនេះ គឺយើងត្រូវវិភាគទៅលើចំនុចផ្សេងៗទៀត រួមមានការផលិត ឬបច្ចេកទេសធ្វើ សមាសធាតុផ្សំក្នុងដីឥដ្ឋ ក្បាច់លម្អ ទំនាក់ទំនង និងឥទ្ធិពលខាងផ្នែកសិប្បកម្ម ពាណិជ្ជកម្ម និងការប្រើប្រាស់។ ចំនុចទាំងនេះខ្ញុំនិងលើកយកមកបង្ហាញក្នុងអត្ថបទបន្តបន្ទាប់។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា





រូបលេខ១៖ ជន្ទាប់មានបាតមូល





រូបលេខ២៖ ជន្ទាប់មានជើង



រូបលេខ៣៣៖ ខួចមានស្រទាប់រលោង



រូបលេខ៣៤៖ កោដ្ឋមានស្រទាប់រលោង

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៥៖ ពែងមានលាបទឹកដីឥដ្ឋ



រូបលេខ២៦៖ ចានមានស្រទាប់រលោង



រូបលេខ៧៖ ក្រឡមានស្រទាប់រលោង



រូបលេខ៨៖ កន្ធិនមានស្រទាប់រលោង



រូបលេខ៩៖ ក្អមមានស្រទាប់រលោង



រូបលេខ១០៖ ផើងមានរន្ធនៅបាត



រូបលេខ១១៖ ពាង់គ្មានស្រទាប់រលោង



រូបលេខ១២៖ ក្បឿងផ្ការ ឬក្បឿងញី



រូបលេខ១៣៖ ក្បឿងផ្កាប់ ឬឈ្មោល



រូបលេខ១៤៖ ក្បឿងវងស្លូវ



រូបលេខ១៥៖ ក្បឿងសន្ទឹករកា

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

# ឯកសារយោង

ឯម សុជាតា

២០០៤. កុលាលភាជន៍ឡខ្នារពោធិ, , និក្ខេបទបរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

ឆាយ រចនា និងទាំងអស់

២០១០. *ស្ថានីយ៍ឡបង្កោង និងកិច្ចអភិរក្ស*, អាជ្ញាធរជាតិអប្សរា, សៀមរាប។

ឆាយ វិសុទ្ធ ចាប សោភារ៉ា

២០០៦. កុលាលភាជន៍ឡអន្លង់ធំ, និក្ខេបទបរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា

២០០៣. *កុលាលភាជន៍ឡសរសី*, សារណាបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា

២០២១. *ស្វែងយល់ខ្លះៗអំពីការស្រាវជ្រាវកុលាលភាជន៍ខ្មែរសម័យអង្គរ*, ក្នុង AMS ,ភ្នំពេញ។

*Analyze on Khmer Unglazed, Green and Brown Glaze Wares*, in Western Prasat Top Site Survey Report, Nara Institute, Japan

Bernard Phillipe, Groslier,

1981. *Khmer Ceramics 9th-14th Century*, Singapore.

Sok Keo Sovannara

2012. *Khmer Stoneware Ceramic from Western Top Temple-Preliminary*.

The Agency for Culture Affaire, Nara National Cultural Properties Research Institute, Japan. The Apsara Authority

2000. *Recent Research on Kiln Sites in Angkor Area*, in Journal of Khmer Study ***Udaya***, n°1, 2000, pp.225-234.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION